**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកំពង់ឆ្នាំង**
លេខ៖ ១១៤/២១..ស.ស.រ

# សេចក្ដីសម្រេច

## ស្ដីពីការបិទជាបណ្ដោះអាសន្នផ្សារសាលាលេខ៥ ក្នុងភូមិសាលាឃុំអូរឫស្សី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង

## អភិបាល នៃគណៈអភិបាលខេត្តកំពង់ឆ្នាំង

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/នកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៧/៥៩៦ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៧ ស្ដីពីការតែងតាំងអភិបាល នៃគណៈអភិបាលខេត្តកំពង់ឆ្នាំងក្នុងដែនសមត្ថកិច្ចដដែល
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទីភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង និងក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- យោងរបាយការណ៍ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២១ របស់មន្ទីរសុខាភិបាលខេត្តកំពង់ឆ្នាំង
- យោងតាមការចាំបាច់របស់រដ្ឋបាលខេត្តកំពង់ឆ្នាំង

## សម្រេច

**ប្រការ ១.-**

ត្រូវបិទជាបណ្ដោះអាសន្នផ្សារសាលាលេខ៥ ស្ថិតក្នុងភូមិសាលាលេខ៥ ឃុំអូរឫស្សី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ចាប់ពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២១ តទៅ និងមានវិធានការដូចខាងក្រោម៖

- ផ្អាកសកម្មភាពលក់ដូរ និងការចេញ-ចូលផ្សារសាលាលេខ៥ ជាបណ្ដោះអាសន្ន
- ចំពោះអាជីវករ និងអ្នកធ្លាប់ចេញ-ចូលផ្សារសាលាលេខ៥ ត្រូវតាមដានសុខភាពរបស់ខ្លួនជាប្រចាំ បើមានរោគសញ្ញាសង្ស័យ ត្រូវប្រញាប់ទំនាក់ទំនងមកក្រុមការងារ ឬមណ្ឌលសុខភាពដែលនៅជិតបំផុត ដើម្បីយកសំណាកទៅពិនិត្យ។

ការបិទជាបណ្ដោះអាសន្នទីតាំងខាងលើនេះ ដើម្បីទប់ស្កាត់ការរាលដាលជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ "សហគមន៍ ២០កុម្ភៈ" បន្ទាប់ពីរដ្ឋបាលខេត្តបានទទួលលទ្ធផលពីវិទ្យាស្ថានសុខភាពសាធារណៈ រកឃើញអ្នកវិជ្ជមានជំងឺកូវីដ-១៩ ចំនួន ៤នាក់ នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២១។

អាជ្ញាធរ និងកងកម្លាំងមានសមត្ថកិច្ច រដ្ឋបាលស្រុកកំពង់ត្រឡាចមានភារកិច្ចរៀបចំបិទបណ្ដោះអាសន្នផ្សារសាលាលេខ៥ ស្របតាមលក្ខណៈបច្ចេកទេស និងនីតិវិធី ព្រមទាំងមានភាពមត់ចត់។

**ប្រការ ២.-**

ចំពោះបងប្អូនដែលមានការពាក់ព័ន្ធផ្ទាល់ ឬប្រយោលក្នុងព្រឹត្តិការណ៍ខាងលើ សូមអញ្ជើញមកជួបក្រុមការងារ ដើម្បីយកសំណាកទៅធ្វើតេស្តជាបន្ទាន់ នៅមន្ទីរពេទ្យបង្អែកកំពង់ត្រឡាច ចាប់ពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២១ នេះតទៅ រៀងរាល់ពេលម៉ោងធ្វើការ និងត្រូវធ្វើចត្តាឡីស័កស្របតាមការណែនាំ។

**ប្រការ ៣.-**

សេចក្ដីសម្រេចណាដែលមានខ្លឹមសារផ្ទុយត្រូវទុកជានិរាករណ៍។

**ប្រការ ៤.-**

នាយករដ្ឋបាលសាលាខេត្ត ស្នងការនគរបាលខេត្ត មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង មេបញ្ជាការកងរាជអាវុធហត្ថខេត្ត ប្រធានមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត អភិបាល នៃគណៈអភិបាលក្រុង ស្រុក ប្រធានមន្ទីរ អង្គភាព និងរដ្ឋបាលឃុំ សង្កាត់ពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសៅរ៍ ១៣កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤
កំពង់ឆ្នាំង ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២១

**អភិបាលខេត្ត**

ឈួរ_ច័ន្ទឡឿន

**កន្លែងទទួល** ÷
- ក្រសួងមហាផ្ទៃ
- ក្រសួងសុខាភិបាល
- ក្រុមប្រឹក្សាខេត្តកំពង់ឆ្នាំង
  *"ដើម្បីជូនជ្រាប"*
- ដូចប្រការ៤
  *"ដើម្បីអនុវត្ត"*
- ឯកសារ-កាលប្បវត្តិ